**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ...៩៤៧.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## ជម្រាបជូន

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តក្រចេះ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥។

**យោង ៖** -របាយការណ៍ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន ១៥ ក្រុមហ៊ុន ស្ថិតក្នុងខេត្តក្រចេះ រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**-ខេត្តក្រចេះ**

**១-ក្រុមហ៊ុន ញូ ឡាញ ខេមភីធីវ៉ាយ អិលធីឌី** (NEW LINE CAM PTY.,LTD) ៖

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ញូ ឡាញ ខេមភីធីវ៉ាយ អិលធីឌី** (NEW LINE CAM PTY., LTD) ដែលមានទីតាំងស្ថិតនៅ ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃចំនួន ៨.៤៦១ (ប្រាំបីពាន់បួនរយហុកសិបមួយ) ហិកតា ជាដីដែលបានចុះបញ្ជីរួច ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២- ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ញូ ឡាញ ខេមភីធីវ៉ាយ អិលធីឌី** (NEW LINE CAM PTY., LTD) ឡើងវិញឱ្យបានច្បាស់លាស់ និងជំរុញការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- កែសម្រួលអនុក្រឹត្យលេខ **១៨៧.អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៨.៩៧៧ (**ប្រាំបីពាន់ប្រាំបួនរយចិតសិបប្រាំពីរ**) **ហិកតា** ស្ថិតនៅក្នុងភូមិសាស្រ្តស្រុកសំបូរ ខេត្តក្រចេះ។

**២-ក្រុមហ៊ុន ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាក្រារូខូ)** (DAUTIENG-KRATIE RUBBER DEVELOPMENT COMPANY LIMITED (DAKRARUCO) ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាក្រារូខូ)** (DAUTIENG-KRATIE RUBBER DEVELOPMENT COMPANY LIMITED (DAKRARUCO) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានឈូសឆាយរួច ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ដូវទៀង ក្រចេះ រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាក្រារូខូ)** (DAUTIENG-KRATIE RUBBER DEVELOPMENT COMPANY LIMITED (DAKRARUCO) ឡើងវិញឲ្យបានច្បាស់លាស់ និងជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- កែសម្រួលអនុក្រឹត្យលេខ **១៧៨.អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៦.៥៩២ (ប្រាំមួយពាន់ប្រាំរយកៅសិបពីរ) ហិកតា** ស្ថិតនៅក្នុងភូមិសាស្រ្ត ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៣-ក្រុមហ៊ុន ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ)** (DAUTIENG (CAMBODIA) RUBBER DEVELOPMENT COMPANY LIMITED (DACAMRUCO)៖

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ)** (DAUTIENG (CAMBODIA) RUBBER DEVELOPMENT COMPANY LIMITED (DACAMRUCO) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែល

បានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ដូវទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវឡុបមេន ខមភេនី លីមីធីត (ដាខេមរូខូ)** (DAUTIENG (CAMBODIA) RUBBER DEVELOPMENT COMPANY LIMITED (DACAMRUCO) ឡើងវិញឱ្យបានច្បាស់លាស់ និងជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

៤- កែសម្រួលអនុក្រឹត្យលេខ **១៧៣ អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៧.៩៧២ (ប្រាំពីរពាន់ប្រាំបួនរយចិតសិបពីរ) ហិកតា** ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៤-ក្រុមហ៊ុន អាយ ភី ឌី អ៊ិនស្តេន ប្រូ ត្រេឌីង** (I P D INSTANT PRO TRADING Co.,Ltd) ៖

១-និរាករណ៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **អាយ ភី ឌី អ៊ិនស្តេន ប្រូ ត្រេឌីង** (I P D INSTANT PRO TRADING Co.,Ltd) ដែលមានទីតាំងស្ថិតនៅក្នុងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ។

២-និរាករណ៍លិខិតលេខ **៦៧៤ សជណ** ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុន **អាយ ភី ឌី អ៊ិនស្តេន ប្រូ ត្រេឌីង** (I P D INSTANT PRO TRADING Co.,Ltd) លើផ្ទៃដីចំនួន **៩៨៧ (ប្រាំបួនរយប៉ែតសិបប្រាំពីរ) ហិកតា** សម្រាប់វិនិយោគដាំកៅស៊ូ ដែលមានទីតាំងស្ថិតនៅក្នុងឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ និងសិទ្ធិប្រទានលេខ **៣៧.សប្រទ** ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល និងកិច្ចសន្យា ស្តីពីការវិនិយោគដាំដំណាំកៅស៊ូ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **អាយ ភី ឌី អ៊ិនស្តេន ប្រូ ត្រេឌីង** (I P D INSTANT PRO TRADING Co.,Ltd) ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១០ មានរយៈពេល **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

**៥-ក្រុមហ៊ុន ហេង ហេង សម្បត្តិចំការកៅស៊ូ** (១) ៖

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ហេង ហេង សម្បត្តិចំការកៅស៊ូ** ដែលមានទីតាំងស្ថិតនៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៩៦ (កៅសិបប្រាំមួយ) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ ពិនិត្យតាមដានគម្រោងវិនិយោគរបស់ក្រុមហ៊ុន **ហេង ហេង សម្បត្តិចំការកៅស៊ូ** ដោយជំរុញការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

**៦-ក្រុមហ៊ុន ហេង ហេង សម្បត្តិចំការកៅស៊ូ** (២) ៖

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ហេង ហេង សម្បត្តិចំការកៅស៊ូ** ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៩៥ (កៅសិបប្រាំបួន) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ ពិនិត្យតាមដានគម្រោងវិនិយោគរបស់ក្រុមហ៊ុន **ហេង ហេង សម្បត្តិចំការកៅស៊ូ** ដោយជំរុញការធ្វើផែនការមេឱ្យបានឆាប់រហ័ស។

**៧-ក្រុមហ៊ុន ស៊ុន គុយទី អ៊ីមផត អិចផត** (SUN KUYTY IMPORT & EXPORT Co.,Ltd) ៖

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ស៊ុន គុយទី អ៊ីមផត អិចផត (SUN KUYTY IMPORT & EXPORT Co.,Ltd)** ដែលមានទីតាំងស្ថិតនៅ ឃុំក្បាលដំរី ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ស៊ុន គុយទី អ៊ីមផត អិចផត (SUN KUYTY IMPORT & EXPORT Co.,Ltd)** ឡើងវិញឱ្យបានច្បាស់លាស់ និងជំរុញ ការចុះបញ្ជីដីរដ្ឋ និងការធ្វើផែនការមេឱ្យបានឆាប់រហ័ស។

**៨-ក្រុមហ៊ុន** Hai Yong Investment Agro Industry Company ៖

១- អនុញ្ញាត់ឱ្យក្រុមហ៊ុន **Hai Yong Investment Agro Industry Company** ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់. និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **Hai Yong Investment Agro Industry Company** ឡើងវិញឱ្យបានច្បាស់លាស់ និងជំរុញការធ្វើផែនការមេឱ្យបានឆាប់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៩-ក្រុមហ៊ុន ថេរវិនិយោ ៖**

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ថេរវិនិយោ** ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ថេរវិនិយោ** ឡើងវិញឲ្យបានច្បាស់លាស់ ដោយជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

**១០-ក្រុមហ៊ុន រតនៈ ស្តោន ខេមបូឌា ឌីវេឡុបមេន ៖**

១- អនុញ្ញាតឱ្យក្រុមហ៊ុន **រតនៈ ស្តោន ខេមបូឌា ឌីវេឡុបមេន** ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **រតនៈ ស្តោន ខេមបូឌា ឌីវេឡុបមេន** ឡើងវិញឱ្យបានច្បាស់លាស់ ដោយជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

**១១-ក្រុមហ៊ុន J P E Co.,Ltd ៖**

១- អនុញ្ញាតឱ្យក្រុមហ៊ុន J P E Co.,Ltd ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **J P E Co.,Ltd** ឡើងវិញឱ្យបានច្បាស់លាស់ និងជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

**១២-ក្រុមហ៊ុន ខូ ខេ អេស អេម លីន លីមីតធីត ៖**

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ខូ ខេ អេស អេម លីន លីមីតធីត** ដែលមានទីតាំងស្ថិតនៅ ឃុំចង្ក្រង់ ស្រុកចិត្របុរី **(អតីត ឃុំចង្ក្រង់ ស្រុកក្រចេះ)** ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដាំដុះរួចចំនួន **១០០ (មួយរយ) ហិកតា** ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ខូ ខេ អេស អេម លីន លីមីតធីត** ឡើងវិញឱ្យបានច្បាស់លាស់ និងជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

**១៣-ក្រុមហ៊ុន ធី វីន (ខេមបូឌា) អិលធីឌី ៖**

១- អនុញ្ញាតឱ្យក្រុមហ៊ុន **ធី វីន (ខេមបូឌា) អិលធីឌី** ដែលមានទីតាំងស្ថិតនៅ ឃុំចង្រ្កង់ ស្រុកចិត្របុរី **(អតីត ឃុំចង្រ្កង់ ស្រុកក្រចេះ)** ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានឈូសឆាយរួច ហើយចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ធី វីន (ខេមបូឌា) អិលធីឌី** ឡើងវិញឱ្យបានច្បាស់លាស់ ដោយជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

**១៤-ក្រុមហ៊ុន C I V Development Agro Industry ៖**

១- និរាករណ៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន C I V Development Agro Industry ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ និងឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ។

២- និរាករណ៍លិខិតលេខ **១៧១០ សជណ** ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការសម្រេចយល់ព្រមផ្តល់ដីសម្បទានជូនក្រុមហ៊ុន C I V Development Agro Industry លើផ្ទៃដីទំហំ **១.០០០ (មួយពាន់) ហិកតា** សម្រាប់វិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំងស្ថិតនៅស្រុកស្នួល ខេត្តក្រចេះ និងកិច្ចសន្យា ស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចដាំដំណាំកៅស៊ូ រវាងសាលាខេត្តក្រចេះ និងក្រុមហ៊ុន C I V Development Agro Industry ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៨ លើផ្ទៃដីចំនួន **៧៦៩ (ប្រាំពីររយហុកសិបប្រាំបួន) ហិកតា** ដែលមានទីតាំងស្ថិតនៅ ឃុំ២ធ្នូ និងឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ និងមានរយៈពេលវិនិយោគ **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**១៥-ក្រុមហ៊ុន ហាមុនី ផ្លានថេសិន ខូ អិល ធី ឌី ៖**

១- និរាករណ៍គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ហាមុនី ផ្លានថេសិន ខូ អិល ធី ឌី** ដែលមានទីតាំងស្ថិតនៅ ឃុំចង្រ្កង់ ស្រុកចិត្របុរី **(អតីត ឃុំចង្រ្កង់ ស្រុកក្រចេះ)** ខេត្តក្រចេះ ។

២- និរាករណ៍លិខិតលេខ **២៧២១/២៧៧ កសក.នផ.ផក** ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកិច្ចសន្យា ស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចដាំដំណាំកៅស៊ូ រវាងសាលាខេត្តក្រចេះ និងក្រុមហ៊ុន **ហាមុនី ផ្លានថេសិន ខូ អិល ធី ឌី** ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៨ លើផ្ទៃដី **៦២៣ (ប្រាំមួយរយម្ភៃបី) ហិកតា** ដែលមានទីតាំងស្ថិតនៅឃុំចង្រ្កង់ ស្រុកចិត្របុរី **(អតីត ឃុំចង្រ្កង់ ស្រុកក្រចេះ)** ខេត្តក្រចេះ និងមានរយៈពេលវិនិយោគ **៧០ (ចិតសិប) ឆ្នាំ**។

៣-ប្រគល់ផ្ទៃដីដកហូតទាំងអស់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៩- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**តឹករ៉េត សំរេច**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងបរិស្ថាន
-ក្រសួងរ៉ែ និងថាមពល
-អង្គភាពប្រឆាំងអំពើពុករលួយ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង
និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ឯកសារ-កាលប្បវត្តិ